# បន្ទាប់ពីមរណភាព

## តើយើងនឹងជួបអ្វីបន្ទាប់ពីមរណភាព?



ទូទាំងប្រទេសកម្ពុជាយើង មានមនុស្ស២០០០នាក់ដែលទទួលមរណភាពរៀងរាល់សប្ដាហ៍។ តើព្រលឹងវិញ្ញាណរបស់ប្រជាជនទាំងនេះ ផុតទៅណាហើយជួបអ្វីបន្ទាប់ទៀត? ចុះយើងវិញ ពេលយើងឈានដល់ថ្ងៃចុងក្រោយរបស់យើង តើយើងនឹងជួបអ្វីបន្ទាប់ពីមរណភាព?

មានយោបល់ផ្សេងៗគ្នាអំពីអ្វីដែលអាចកើតឡើងបន្ទាប់ពីជីវិតនេះ ប៉ុន្តែ តើមួយណាជារឿងពិត? ក្នុងកូនសៀវភៅនេះ យើងឆ្លើយសំណួរនេះ មិនមែនដោយដកស្រង់គំនិតស្មានរបស់មនុស្សទេ ប៉ុន្តែដោយដកស្រង់ចម្លើយជាក់លាក់ពីព្រះគម្ពីររបស់ព្រះជាម្ចាស់ គឺជាព្រះអង្គដែលប្រទានជីវិត ហើយក៏ដកជីវិតយកវិញដែរ។ យើងមិនចាំបាច់ឆ្ងល់ ឬគិតស្មានអំពីរឿងនេះទៀតទេ ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបំភ្លឺដើម្បីឲ្យយើងដឹងច្បាស់លាស់ អំពីអ្វីដែលនឹងកើតឡើងបន្ទាប់ពីមរណភាព។

ព្រះជាម្ចាស់ចង់ឲ្យយើង យល់អំពីព្រឹត្តិការណ៍អនាគតមួយចំនួនដែលយើងត្រូវជួបប្រទះ ដើម្បីឲ្យយើងមានប្រាជ្ញាដែលស្វែងយល់ពីទីបញ្ចប់របស់យើងផ្ទាល់ ហើយត្រៀមខ្លួនមុនពេលផុតកំណត់។ នៅក្នុងបទគម្ពីរមួយ ព្រះអង្គមានបន្ទូលថា៖

*«ប្រសិនបើគេមានប្រាជ្ញា គេមុខជាយល់សេចក្ដីនេះ គេនឹងយល់ពីចុងបំផុតរបស់គេជាយ៉ាងណាមិនខាន!»*[1]



ដូច្នេះ សូមអានព្រះគម្ពីរខាងក្រោមនេះដោយពិចារណា ដើម្បីស្វែងយល់ពីរឿងសំខាន់ៗបីយ៉ាងដែលយើងត្រូវជួបប្រទះបន្ទាប់ពីមរណភាព៖

### ១. បន្ទាប់ពីមរណភាព រូបកាយយើងនឹងត្រឡប់ទៅជាដីវិញ ហើយព្រលឹងវិញ្ញាណយើងនឹងឡើងទៅជួបព្រះជាម្ចាស់។

ព្រះជាម្ចាស់មានបន្ទូលថា៖ «ដោយព្រោះអ្នក[បានធ្វើអ្វីដែលយើងបានហាម] អ្នកនឹង...ត្រឡប់ទៅជាដីវិញ ដ្បិតយើងបានយកអ្នកពីដីមក...ហើយអ្នកនឹងត្រឡប់ទៅជាធូលីដីវិញ»[2] □ «ធូលីត្រឡប់ជាដីដូចដើមវិញ ហើយវិញ្ញាណត្រឡប់ទៅឯព្រះ ដែលព្រះអង្គបានប្រទានមកនោះ»[3] □«តម្រូវឲ្យមនុស្សលោកទាំងអស់ស្លាប់ម្ដង រួចមកត្រូវទទួលការជំនុំជំរះយ៉ាងណា។»[4]

### ២. បន្ទាប់ពីមរណភាព ព្រះជាម្ចាស់នឹងជំនុំជំរះមនុស្សលោក ហើយនឹងតម្រូវឲ្យយើងម្នាក់ៗ រៀបរាប់ទូលថ្វាយព្រះពីគ្រប់ទាំងអំពើដែលខ្លួនយើងបានប្រព្រឹត្ត។

«ព្រះអង្គបាន កំណត់ថ្ងៃមួយ ទុកដែលនឹង ជំនុំជំរះមនុស្ស លោកដោយ សុចរិត»[5] 🕮




«ទាំងអ្នកធំ ទាំងអ្នកតូច ឈរនៅមុខបល្ល័ង្ក ហើយ បញ្ជីក៏បើកឡើង ... រួចមនុស្សស្លាប់ទាំងអស់ត្រូវជំនុំជម្រះ តាមអំពើដែលគេបានប្រព្រឹត្ត ដូចមានកត់ត្រាទុកក្នុងបញ្ជីទាំងនោះ។»[6] 🕮 «ដូច្នេះ យើងម្នាក់ៗនឹងត្រូវរៀបរាប់ទូលថ្វាយព្រះ ពីគ្រប់ទាំងអំពើដែលខ្លួនបានប្រព្រឹត្ត។»[7] 🕮 «នៅថ្ងៃជំនុំជំរះ មនុស្សនឹងត្រូវរៀបរាប់ប្រាប់ ពីអស់ទាំងពាក្យឥតប្រយោជន៍ដែលគេបាននិយាយ ... ហើយក៏នឹងជាប់ទោសដោយសារតែពាក្យសម្ដីរបស់ខ្លួនដែរ»[8] 🕮 «ចូរកោតខ្លាចដល់ព្រះ ...ព្រះនឹងនាំគ្រប់ការទាំងអស់មកដើម្បីជំនុំជម្រះ ព្រមទាំងអ្វីៗដែលលាក់កំបាំងផង ទោះល្អ ឬអាក្រក់ក្ដី។»[9] 🕮 «មើល៍ យើងខ្ញុំនៅចំពោះព្រះអង្គទាំងជាប់មានបាប ដ្បិតដោយព្រោះអំពើបែបនេះ គ្មានអ្នកណាអាចឈរនៅចំពោះព្រះអង្គបានឡើយ។»[10]

## ៣. បន្ទាប់ពីមរណភាព ព្រះជាម្ចាស់នឹងដាក់ទោសអស់អ្នកដែលមិនបានប្រែចិត្ត និងទទួលជឿព្រះយេស៊ូវ។

«ដោយអ្នក ... មិនព្រមប្រែចិត្ត នោះអ្នកកំពុងតែប្រមូលសេចក្ដីក្រោធ ទុកសម្រាប់ខ្លួននៅថ្ងៃនៃសេចក្ដីក្រោធវិញ ជាថ្ងៃដែលព្រះនឹងសម្ដែងការជំនុំជំរះដ៏សុចរិត។»[11] 🕮 «អស់អ្នកដែលមិនស្ដាប់តាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង គេនឹងទទួលទោសជាសេចក្ដីអន្តរាយអស់កល្បជានិច្ច គឺឃ្លាតពីព្រះភក្ត្រព្រះអម្ចាស់។»[12]

## ៤. បន្ទាប់ពីមរណភាព ព្រះជាម្ចាស់នឹងទទួលស្វាគមន៍អស់អ្នកដែលបានទទួលការលើកលែងទោសបាប គឺជាអ្នកដែលបានប្រែចិត្ត និងទទួលជឿព្រះយេស៊ូវ។

«ដ្បិតឈ្នួលរបស់បាប ជាសេចក្ដីស្លាប់ តែអំណោយទានរបស់ព្រះវិញ គឺជីវិតអស់កល្បជានិច្ច នៅក្នុងព្រះគ្រីស្ទយេស៊ូវ»[13] 🕮 «ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង បានជាទ្រង់ប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ (គឺជាព្រះយេស៊ូវ) ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ។»[14] 🕮 «ព្រះគ្រីស្ទយេស៊ូវបានយាងមកក្នុងពិភពលោក ដើម្បីសង្គ្រោះមនុស្សបាប»[15] 🕮 «ព្រះអង្គមិនបានធ្វើបាបសោះ...(តែ)ព្រះអង្គបានផ្ទុកអំពើបាបរបស់យើងក្នុងព្រះកាយព្រះអង្គដែលជាប់លើឈើឆ្កាង»[16]🕮«(ព្រះ)លុបចោលសេចក្ដីដែលកត់ទុកទាស់នឹងយើង... ដោយបោះភ្ជាប់នៅនឹង



ឈើឆ្កាង។»[17] «ព្រះយេស៊ូវត្រូវគេបញ្ជូនទៅសម្លាប់ ដោយព្រោះអំពើរំលងរបស់យើង ហើយព្រះបានប្រោសឲ្យមានព្រះជន្មរស់ឡើងវិញ ដើម្បីឲ្យយើងបានសុចរិត។»[18] 🕮 «អ្នកណាដែលជឿដល់ព្រះរាជបុត្រា អ្នកនោះមានជីវិតអស់កល្បជានិច្ច តែអ្នកណាដែលមិនព្រមជឿដល់ព្រះរាជបុត្រាវិញ អ្នកនោះនឹងមិនឃើញជីវិតឡើយ គឺសេចក្ដីក្រោធរបស់ព្រះ តែងនៅជាប់លើអ្នកនោះជានិច្ច»[19]

ឥឡូវនេះ លោកអ្នកបានអាន ឬបានឮព្រះបន្ទូលរបស់ព្រះអំពីអ្វីដែលយើងត្រូវជួបប្រទះ បន្ទាប់ពីមរណភាព មើល៍ ព្រះជាម្ចាស់បានដាក់ផ្លូវពីរនៅមុខយើង គឺ**ផ្លូវជីវិត** និង**ផ្លូវស្លាប់** យើងត្រូវជ្រើសរើសតែមួយប៉ុណ្ណោះ។[20] សូមស្ដាប់សំឡេងព្រះអង្គដែលកំពុងហៅលោកអ្នក ឲ្យងាកចេញពី**ផ្លូវស្លាប់**ដែលនាំទៅសេចក្ដីវិនាសអន្តរាយ ហើយកំពុងអញ្ជើញលោកអ្នក ឲ្យជ្រើសរើស**ផ្លូវជីវិត**ដែលនាំទៅមិត្តភាពដ៏រីករាយជាមួយព្រះយេស៊ូវជារៀងរហូត! ដូច្នេះ សូមមានប្រាជ្ញាឡើង ដោយងាកចេញពីផ្លូវអាក្រក់ ហើយ

ជ្រើសរើសផ្លូវល្អប្រសើរវិញ។ ហេតុអ្វីចង់ទទួលទណ្ឌកម្ម យ៉ាងធ្ងន់ធ្ងរ ហើយក៏រងទុក្ខជារៀងរហូត? ពិតជាយើងសមនឹងទទួលលទ្ធផលនេះ



ប៉ុន្តែ យើងមិនចាំបាច់ទទួលទោសនេះទេ ដ្បិតនៅលើឈើឆ្កាង ព្រះយេស៊ូវបានរងទុក្ខទោសរបស់យើងរួចហើយ ហេតុនេះ ប្រសិនបើយើងទទួលជឿព្រះយេស៊ូវ នោះព្រះជាម្ចាស់នឹង លុបចោលសេចក្តីដែលកត់ទុកទាស់នឹងយើងក្នុងបញ្ជី ដូច្នេះ សូមព្រមទទួលការលើកលែងទោសបាប ដែលព្រះជាម្ចាស់ប្រុងប្រៀបប្រទានឲ្យលោកអ្នក។

ហេតុអ្វីព្រមចុះចាញ់នឹងទុក្ខវេទនានៅខាងមុខ? យើងមិនចាំបាច់ រស់នៅដោយភាពអស់សង្ឃឹមនេះទេ ព្រោះបីថ្ងៃបន្ទាប់ពីព្រះយេស៊ូវបានសុគត ព្រះអង្គបានរស់ពីស្លាប់ឡើងវិញ! ព្រះយេស៊ូវបានឈ្នះលើសេចក្តីស្លាប់រួចហើយ ហើយនៅថ្ងៃបន្តិចទៀត ព្រះអង្គនឹងយាងមកពីស្ថានសួគ៌ម្តងទៀត ដើម្បីបំផ្លាញចោលសេចក្តីស្លាប់ ហើយបណ្តេញចេញទុក្ខវេទនាផុតទៅដែរ នៅថ្ងៃនោះ «សេចក្តីស្លាប់នឹងលែងមានទៀតហើយ ការកាន់ទុក្ខ ការយំសោក ឬការឈឺចាប់ ក៏នឹងលែងមានទៀតដែរ»[21] ហើយព្រះអង្គនឹងជូតអស់ទាំងទឹកភ្នែក ចេញពីភ្នែករបស់ប្រជារាស្ត្ររបស់ព្រះអង្គ។

បងប្អូនអើយ ព្រោះទាំងអស់នេះជាការពិត សូមបោះជំហានដំបូងតាមផ្លូវជីវិត សូមទូលអង្វរព្រះពីដួងចិត្តដែលចង់ប្រែចិត្តពីអំពើបាប ហើយព្រមទទួលជឿព្រះយេស៊ូវ។ ព្រះអង្គរង់ចាំជួយសង្គ្រោះលោកអ្នកឲ្យរួចពីបាប ហើយរង់ចាំស្វាគមន៍ឲ្យចូលរួមក្នុងមិត្តភាពជាមួយព្រះអង្គចាប់ពីថ្ងៃនេះតទៅជារៀងរហូត។

សូមកុំស្ទាក់ស្ទើរយូរពេក ជីវិតយើងមិនទៀងទេ ហើយអាយុយើងកន្លងទៅយ៉ាងលឿនផង។ យើងទាំងអស់គ្នា ហៀបនឹងទៅជួបព្រះជាម្ចាស់ដែលត្រូវវិនិច្ឆ័យយើងម្នាក់ៗ ដូច្នេះ សូមត្រៀមខ្លួននៅថ្ងៃនេះ ក្រែងលោនឹងស្តាយយ៉ាងខ្លាំងនៅថ្ងៃក្រោយ។

**ឯកសារយោងបទគម្ពីរ**

*ខគម្ពីរដកស្រង់ពីព្រះគម្ពីរបរិសុទ្ធកែសម្រួល ២០១៦*

[1]ចោទិយកថា ៣២.២៩ [2]លោកុប្បត្តិ ៣.១៧-១៩ [3]សាស្តា ១២.៧ [4]ហេព្រើរ ៩.២៧ [5]កិច្ចការ ១៧.៣០-៣១ [6]វិវរណៈ ២០.១២-១៥ [7]រ៉ូម ១៤.១២ [8]ម៉ាថាយ ១២.៣៦-៣៧ [9]សាស្តា ១២.១៣-១៤ [10]អេសាយ ៩.១៥ [11]រ៉ូម ២.៥-៦ [12]២ថែស្សាឡូនីច ១.៨-៩ [13]រ៉ូម ៦.២៣ [14]យ៉ូហាន ៣.១៦ [15]១ធីម៉ូថេ ១.១៥ [16]១ពេត្រុស ២.២២-២៤ [17]កូឡុងស ២.១៣-១៤ [18]រ៉ូម ៤.២៥ [19]យ៉ូហាន ៣.៣៦ [20]យេរេមា ២១.៨ [21]វិវរណៈ ២១.៤

**សហគមន៍ស្វែងរកប្រាជ្ញានៃព្រះគម្ពីរព្រះយេស៊ូវ**

www.facebook.com/SeekingtheWisdomofJesusinKhmer www.youtube.com/@swoj

***សូមព្រះប្រទានពរលោកអ្នកតាមព្រះបន្ទូលទាំងនេះ។***